# តើអ្វីទៅហៅថា TOR?

## The Onion Router

- TOR គឺជាពាក្យកាត់មកពី The Onion Router
- កម្មវិធី TOR ត្រូវបានផលិតដោយមន្ទីរពិសោធន៍ស្រាវជ្រាវនៃកងទ័ពជើងទឹកសហរដ្ឋអាមេរិក ដើម្បីការពារព័ត៌មានក្នុងការប្រាស្រ័យទាក់ទងរបស់សហរដ្ឋអាមេរិក។
- TOR មានបំណងការពារអត្តសញ្ញាណអ្នកប្រើប្រាស់ និង សកម្មភាពលើអ៊ីនធឺណិតរបស់ពួកគេពីការឃ្លាំមើល និងការវិភាគផ្សេងៗលើអ៊ីនធឺណិត។
- អ្នកប្រើប្រាស់អាចប្រើ TOR បានដោយស្របដើម្បីរក្សាឯកជនភាពរបស់ពួកគេ។ ចៀសវាងការត្រួតពិត្យ ឬការពារខ្លួនពួកគេពីរបបគាបសង្កត់ ឬការឃ្លាំមើល។

## តើវាដំណើរការយ៉ាងដូចម្តេច?

TOR បង្វែរចរាចរណ៍អ៊ីនធឺណិត ឲ្យឆ្លងកាត់បណ្តាញមួយផ្សេងទៀតដែលលាក់ទីកន្លែង ឬអត្តសញ្ញាណរបស់អ្នកប្រើប្រាស់។ ជំនួសដោយការធ្វើចរាចរណ៍ដោយផ្ទាល់ដូចជាចូលទៅកាន់គេហទំព័រផ្សេងៗ ឬប្រើប្រាស់កម្មវិធីសាររហ័ស (instant messages) ដោយឆ្លងកាត់វិថីអ៊ីនធឺណិតដែលជាក់លាក់ហើយអាចត្រូវបានគេដឹងដោយងាយស្រួល [ឧ. ពីអ្នកប្រើប្រាស់ឈ្មោះគីម ទៅគេហទំព័រមួយ] TOR ធ្វើដំណើរឆ្លងកាត់វិថីអ៊ីនធឺណិតដែលតែងតែប្រែប្រួល ដែលមិនអាចត្រូវបានគេតាមដានរកឃើញឡើយ។

ការតភ្ជាប់របស់ TOR ត្រូវបានចាក់សោរដោយកូដ។ តំណភ្ជាប់ដែលមិនបានចាក់សោអាចត្រូវបានគេឃ្លាំមើល ហើយអាចឲ្យគេដឹងថាតើអ្នកចូលមើលគេហទំព័រអ្វី ដោយធ្វើការតាមដាន អាយភី (IP-address) របស់អ្នក។ ចំណែកឯ TOR វិញគឺប្រើប្រាស់តំណភ្ជាប់ដែលមានការចាក់សោដោយកូដ ដែលមានន័យថាពីអ្នកប្រើប្រាស់អ៊ីនធឺណិតប្រភពដើម ទៅកាន់ទីតាំង ឬគេហទំព័រដែលចង់មើលគឺមិនច្បាស់ទេថាតើទិន្នន័យមកពីកន្លែងណា ឬក៏ទៅកន្លែងណានោះទេ។




នៅពេល គីម មើលគេហទំព័រតាមបណ្តាញ TOR នោះចរាចរណ៍លើបណ្តាញអ៊ីនធឺណឺតរបស់នាងធ្វើដំណើរលើបណ្តាញនានា ឆ្លងកាត់កុំព្យូទ័ររបស់មនុស្សផ្សេងៗទៀត ដើម្បីចូលទៅកាន់គេហទំព័រនោះ។ នៅកណ្តាលព័ត៌មានរវាងប្រភព និងគោលដៅត្រូវបានគេលាក់បាំង ឬ ដកចេញ ដើម្បីធ្វើឲ្យការកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់មានភាពលំបាកបំផុត។ ជាលទ្ធផល អ្នកផ្តល់សេវាកម្មអ៊ីនធឺណិតមិនអាចតាមដានថា នាងជាអ្នកណា ហើយវែបសាយអ្វីខ្លះដែលនាងកំពុងមើលនោះទេ។ ឬដោយធ្វើឲ្យយល់ច្រឡំ TOR បង្ហាញនូវចំណុចចចុងក្រោយ [Josie] ថាជាប្រភពនៃទំនាក់ទំនង។

* អាសយដ្ឋានអាយភី IP-address បង្ហាញឱ្យឃើញនូវអត្តសញ្ញាណអ្នកប្រើប្រាស់ឧបករណ៍ [សូមមើលតារាងព័ត៌មាន៖ តើអ្វីទៅហៅថាអាសយដ្ឋានអាយភី IP-address?]

## TOR បានអនុវត្តទៅលើការរំលោភបំពានផ្លូវភេទកុមារ និងការធ្វើអាជីវកម្មលើកុមារតាមអ៊ិនធឺណិត

អ្នកប្រព្រឹត្តបទល្មើសផ្លូវភេទកុមារ ប្រើប្រាស់ TOR ដើម្បីចែករំលែករូបភាពរំលោភបំពានផ្លូវភេទកុមារ ឬសម្ភារៈផ្សេងៗ ដែលជួយសម្រួល និងធ្វើឱ្យមានវប្បធម៌នៃការរំលោភបំពានផ្លូវភេទកុមារ។ លើសពីនេះ TOR អនុញ្ញាតឱ្យពួកគេភ្ជាប់ទំនាក់ទំនងជាមួយជនរងគ្រោះជាលក្ខណៈអាណាមិក។ TOR សេវាកម្មលាក់អត្តសញ្ញាណនេះ បើកឱកាសឱ្យឧក្រិដ្ឋជននានាទាក់ទងគ្នាទៅវិញទៅមកយ៉ាងសម្ងាត់ផងដែរ។ តាមរយៈការប្រើប្រាស់ TOR អ្នកប្រព្រឹត្តបទល្មើសបានចៀសផុតពីការបញ្ចេញឱ្យដឹងនូវទីកន្លែង ឬអត្តសញ្ញាណរបស់ពួកគេ ជាហេតុធ្វើឲ្យក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត (ISPs) និងមន្ត្រីអនុវត្តច្បាប់មិនអាចរកពួគគេឃើញ។ សេវាកម្មរបស់ TOR នេះ គឺធ្វើឱ្យពិបាកឬស្មុគ្រស្មាញដល់ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងអ្នកប្រព្រឹត្តបទល្មើស។

TOR ជាកម្មវិធី ល្បីល្បាញបំផុត ដែលត្រូវបានគេប្រើប្រាស់ផងដែរដើម្បីចូលទៅផ្នែក ឬគេហទំព័រនានានៃអ៊ីនធឺណិត ដែលត្រូវបានបង្កើតឡើងប៉ុន្តែមិនអាចចូលមើលបានជាទូទៅ ឬក៏ពិបាកក្នុងការចូលមើលឬប្រើប្រាស់ ហើយនេះ សំដៅទៅលើគេហទំព័រ "DeepWeb" ឬ "Darknet" (ដែលបង្ហាញអំពីសម្ភារៈ ឬសកម្មភាពខុសច្បាប់នៅទីនោះ)។ ។បណ្តាញកុំព្យូទ័រ សម្ងាត់ ឬអនាមិកទាំងនេះអាចចូលមើល ឬប្រើប្រាស់បានដោយប្រើកម្មវិធីកុំព្យូទ័រពិសេសៗ ដូចជា TOR។

តារាងព័ត៌មាននេះផលិតដោយអង្គការ ECPAT អន្តរជាតិ។ ឧបត្ថម្ភគាំទ្រសម្រាប់ការបកប្រែភាសា និងការផលិតដោយអង្គការ UNICEF។

ecpat
unicef
unite for children